# ត្រូវបានដឹកនាំដោយព្រះវិញ្ញាណដ៏បរិសុទ្ធ

ប្រធាន បិយដ៍ យេ ផាកកឺ
ប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*យើងគ្រប់គ្នាអាចត្រូវបានដឹកនាំ ដោយវិញ្ញាណនៃវិវរណៈ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។*

អស់រយៈពេល 400 ឆ្នាំ មកហើយ តាំងពីព្រះគម្ពីរបរិសុទ្ធ កំណែថ្មីនៃស្តេចជេមស៍បានបោះពុម្ព ដោយមានការចូលរួមយ៉ាងសកម្មពី វិល្លិម ធីនឌែល ដែលជាវីរបុរសដ៏អស្ចារ្យរបស់ខ្ញុំ ។

ពួកអាចារ្យមិនចង់ឲ្យព្រះគម្ពីរបរិសុទ្ធ ត្រូវបោះពុម្ពជាភាសាអង់គ្លេសនោះទេ ។ ពួកគេបានជំរុញ ធីនឌែល ពីកន្លែងមួយទៅកន្លែងមួយ ។ គាត់បាននិយាយទៅពួកគេថា « បើព្រះទុកឲ្យខ្ញុំរស់នៅច្រើនឆ្នាំទៅមុខទៀត នោះខ្ញុំនឹងធ្វើឲ្យក្មេងប្រុសដែលបរនង្គ័លនេះនឹងចេះពីព្រះគម្ពីរច្រើនជាងអ្នកទៅទៀត » ។[1]

ធីនឌែល ត្រូវបានគេក្បត់ ហើយឃុំឃាំងក្នុងគុកដ៏ងងឹត ហើយត្រជាក់ នៅក្នុងរាជធានី ប្រ៊ូសេល អស់ជាងមួយឆ្នាំ ។ សំលៀកបំពាក់របស់គាត់រហែករយ៉ីរយ៉ៃ ។ គាត់បានសុំអ្នកឆ្មាំគុកយកអាវធំ និងមួក និងឈើច្រត់របស់គាត់ ដោយនិយាយថា « វាគួរឲ្យតប់ប្រមល់ណាស់ ដែលអង្គុយម្នាក់ឯងក្នុងភាពងងឹតបែបនេះ » ។[2] គេមិនបានឲ្យគាត់នូវរបស់ទាំងនោះទេ ។ ទីបំផុត គេយកគាត់ចេញពីគុក ហើយគាត់ត្រូវបានគេសម្លាប់ដោយព្យួរក និងដុតនៅលើបង្គោល នៅចំពោះមុខមនុស្សមួយក្រុមធំ ។ ប៉ុន្តែ កិច្ចការ និងមរណភាពដ៏អង់អាចរបស់គាត់ មិនជាអសារឥតការឡើយ ។

ដោយសារកូនចៅរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានបង្រៀន តាំងពីក្មេងឲ្យស្គាល់ព្រះគម្ពីរដ៏បរិសុទ្ធទាំងឡាយ នោះពួកគេបានបំពេញការព្យាករណ៍ ដែលបានព្យាករដោយ វិល្លិម ធីនឌែល កាលពីបួនសតវត្សមុន ។ ព្រះគម្ពីររបស់យើងសព្វថ្ងៃនេះ រួមមាន ព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន ៖ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ មុក្តាដ៏មានតម្លៃមហិមា និងគោល -លទ្ធិ និងសេចក្តីសញ្ញា ។

ដោយសារព្រះគម្ពីរមរមន ជាញឹកញាប់ យើងត្រូវបានគេហៅថាជាសាសនាចក្រមរមន ជាងារមួយដែលមិនបានធ្វើឲ្យយើងអន់ចិត្តទេ ប៉ុន្តែវាពិតជាមិនត្រឹមត្រូវនោះទេ ។

ក្នុងព្រះគម្ពីរមរមន ព្រះអម្ចាស់បានត្រឡប់ទៅជួបពួកសាសន៍នីហ្វៃម្តងទៀត ដោយសារពួកគេបានអធិស្ឋានទៅកាន់ព្រះវរបិតា នៅក្នុងព្រះនាមរបស់ទ្រង់ ។ ព្រះអម្ចាស់មានព្រះបន្ទូលថា « តើអ្នករាល់គ្នាចង់ឲ្យយើងប្រទានអ្វីដល់អ្នក ?

« ហើយពួកគេបានទូលទ្រង់ថា ៖ ឱព្រះអម្ចាស់អើយ យើងខ្ញុំសូមឲ្យព្រះអង្គប្រាប់យើងខ្ញុំនូវឈ្មោះ ដែលយើងខ្ញុំនឹងហៅសាសនាចក្រនេះ ត្បិតមានការប្រកែកគ្នា នៅក្នុងចំណោមប្រជាជនអំពីរឿងនេះ ។

« ហើយព្រះអម្ចាស់ទ្រង់មានបន្ទូលថា ...ហេតុអ្វីបានជាប្រជាជនរអ៊ូរទាំ ហើយប្រកែកគ្នា ដោយសាររឿងនេះ ? »

« តើពួកគេពុំបានអានបទគម្ពីរទាំងឡាយដែលបានចែងថា អ្នករាល់គ្នាត្រូវយកព្រះនាមព្រះគ្រីស្ទដាក់លើខ្លួន...ឬទេ ? ត្បិតដោយនាមនេះហើយដែលអ្នករាល់គ្នានឹងត្រូវបានហៅនៅថ្ងៃចុងក្រោយបង្អស់... ។

« ដូច្នេះ សូម្បីជាអ្វីដែលអ្នករាល់គ្នានឹងធ្វើ នោះអ្នករាល់គ្នាត្រូវធ្វើ ដោយនូវព្រះនាមយើង ដូច្នេះ អ្នករាល់គ្នាត្រូវហៅសាសនាចក្រតាមនាមយើង ហើយអ្នករាល់គ្នាត្រូវអំពាវនាវដល់ព្រះវរបិតា ដោយនូវនាមយើង ប្រយោជន៍ឲ្យទ្រង់ប្រទានពរដល់សាសនាចក្រ ដោយយល់ដល់យើង ។

« ហើយតើនេះជាសាសនាចក្ររបស់យើងដូចម្ដេចកើត លើកលែងតែហៅតាមនាមយើង ? ត្បិតបើសិនជាសាសនាចក្រនេះ ហៅតាមឈ្មោះលោក ម៉ូសេ នោះជាសាសនាចក្ររបស់លោកម៉ូសេហើយ ឬបើសិនជាសាសនាចក្រនេះហៅតាមឈ្មោះរបស់បុរសណាម្នាក់ នោះជាសាសនាចក្ររបស់បុរសនោះហើយ តែបើសិនជាសាសនាចក្រនេះហៅតាមនាមយើង នោះទើបជាសាសនាចក្ររបស់យើង ប្រសិនបើគេសង់លើដំណឹងល្អរបស់យើង » ។[3]

ព្រោះយើងគោរពដល់វិវរណៈ យើងហៅខ្លួនយើងថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាជាងសាសនាចក្រមរមន ។ បើសិនជាអ្នកដទៃហៅសាសនាចក្រថាជា « សាសនាចក្រមរមន » ឬហៅពួកយើងថាជា « ពួកមរមន » វាមិនជាបញ្ហាទេ ប៉ុន្តែវាខុសគ្នាបើយើងហៅខ្លួនឯងនូវពាក្យដូចគ្នានេះ ។

គណៈប្រធានទីមួយបានថ្លែងថា « ឈ្មោះដែលបានបើកសម្ដែងរបស់សាសនាចក្រ គឺជាសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ( គ. និង ស. 115:4 ) គឺសំខាន់ខ្លាំងណាស់នៅក្នុងការទទួលខុសត្រូវរបស់យើងក្នុងការប្រកាសព្រះនាមរបស់ព្រះអង្គសង្គ្រោះ នៅទូទាំងពិភពលោក ។ ហេតុដូច្នេះ យើងសុំថា ពេលយើងធ្វើសេចក្ដីយោងទាំងឡាយចំពោះសាសនាចក្រ គួរតែមាននូវឈ្មោះពេញរបស់សាសនាចក្រតាមដែលអាចធ្វើទៅបាន... ។ នៅពេលហៅសមាជិកសាសនាចក្រ យកល្អគួរតែប្រើឃ្លាថា « សមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។ បើជាការហៅកាត់ នោះហៅថា ' ពួកបរិសុទ្ធថ្ងៃចុងក្រោយ ' គឺជាការប្រសើរជាង » ។[4]

« [ ពួកបរិសុទ្ធថ្ងៃចុងក្រោយ ] និយាយអំពីព្រះគ្រីស្ទ យើងអររីករាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ ហើយយើងសរសេរស្របតាមពាក្យព្យាករណ៍ទាំងឡាយរបស់យើង ដើម្បីឲ្យកូនចៅយើងអាចដឹងថា តើត្រូវស្វែងរកប្រភពណាមួយ ដើម្បីឲ្យបានផ្ដាច់បាបរបស់ពួកគេ » ។[5]

មនុស្សក្នុងលោកនេះនឹងហៅយើងតាមអ្វីដែលគេចង់ ប៉ុន្តែចូរចាំនៅក្នុងការនិយាយរបស់យើងថា យើងជាសមាជិកនៃសាសនាចក្រនៃ*ព្រះយេស៊ូវគ្រីស្ទ* ។

មនុស្សខ្លះធ្វើការជំទាស់ថា យើងមិនមែនជាពួកគ្រីស្ទានទេ ។ ពួកគេមិនស្គាល់យើងសោះតែម្ដង ឬក៏ពួកគេអាចយល់ច្រឡំ ។

នៅក្នុងសាសនាចក្រ គ្រប់ពិធីបរិសុទ្ធត្រូវបានធ្វើឡើងដោយសិទ្ធិអំណាចនិងក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។[6] យើងមានការរៀបចំដូចគ្នា ដូចដែលមាននៅក្នុងសាសនាចក្រពីអតីតកាល ដូចជាពួកសាវក និងពួកព្យាការី ។[7]

កាលពីបុរាណ ព្រះអម្ចាស់បានតែងតាំងសាវក 12 នាក់ ។ ទ្រង់ត្រូវបានគេក្បត់ និងឆ្កាង ។ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានបង្រៀនសាវករបស់ទ្រង់អស់ 40 ថ្ងៃ ហើយបន្ទាប់មកបានយាងទៅស្ថានសួគ៌វិញ ។[8]

ប៉ុន្តែ មានអ្វីមួយដែលខ្វះខាត ។ ពីរបីថ្ងៃក្រោយមក ពួកដប់ពីរនាក់បានប្រមូលគ្នានៅក្នុងផ្ទះមួយ ហើយ « ស្រាប់តែមានឮសូរពីលើមេឃ ដូចជាខ្យល់បក់គំហុកយ៉ាងខ្លាំង មកពេញក្នុងផ្ទះ... ។ ក៏មានអណ្ដាត...ភ្លើង [ មកសណ្ឋិត ] លើគេគ្រប់គ្នា ។ រួចគេបាន...ពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់ » ។[9] ពួកសាវករបស់ទ្រង់បានទទួលអំណាច ។ ពួកគេបានយល់ថា សិទ្ធិអំណាចដែលបានផ្ដល់ដោយព្រះអង្គសង្គ្រោះ និងអំណោយទានព្រះវិញ្ញាណបរិសុទ្ធ គឺចាំបាច់ណាស់ក្នុងការស្ថាបនាសាសនាចក្រ ។ ពួកគេត្រូវបានបញ្ជាឲ្យធ្វើបុណ្យជ្រមុជទឹក និងប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ។[10]

ដោយថាហេតុ ពួកសាវក និងបព្វជិតភាពដែលពួកគេកាន់បានបាត់បង់ទៅ ។ សិទ្ធិអំណាច និងអំណាច ដើម្បីបម្រើត្រូវតែស្ដារឡើងវិញ ។ អស់រយៈពេលជាច្រើនសតវត្ស មនុស្សបានរង់ចាំយ៉ាងអន្ទះសាចំពោះការត្រឡប់មកវិញនូវសិទ្ធិអំណាច និងការស្ថាបនាសាសនាចក្ររបស់ព្រះអម្ចាស់ ។

ក្នុងឆ្នាំ 1829 បព្វជិតភាពត្រូវបានស្ដារឡើងវិញដល់ យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ដោយ យ៉ូហាន បាទីស្ទ និងសាវក ពេត្រុស យ៉ាកុប និងយ៉ូហាន ។ ឥឡូវនេះ សមាជិកបុរសនៃសាសនាចក្រដែលមានភាពសក្ដិសមត្រូវបានតែងតាំងបព្វជិតភាព ។ សិទ្ធិអំណាចនេះ និងអំណោយទានជំនួយនៃព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានប្រគល់ឲ្យដល់សមាជិកទាំងអស់នៃសាសនាចក្របន្ទាប់ពីពិធីបុណ្យជ្រមុជទឹក ធ្វើឲ្យយើងខុសប្លែកពីព្រះវិហារផ្សេងទៀត ។

នៅក្នុងវិវរណៈកាលពីដើមបានណែនាំថា « មនុស្សគ្រប់រូបអាចនិយាយ ដោយនូវព្រះនាមនៃព្រះដ៏ជាព្រះអម្ចាស់ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក » ។[11] កិច្ចការនៅក្នុងសាសនាចក្រសព្វថ្ងៃនេះត្រូវបានធ្វើឡើងដោយបុរស និងស្ត្រីសាមញ្ញ ដែលត្រូវបានហៅ និងគាំទ្រ ដើម្បីធ្វើជាអធិបតី ដើម្បីបង្រៀន និង

ដើម្បីចាត់ចែង ។ វាគឺដោយអំណាចនៃវិវរណៈ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលពួកអ្នកដែលត្រូវបានហៅទាំងនោះត្រូវបានដឹកនាំឲ្យស្គាល់ពីឆន្ទៈរបស់ព្រះ ។ អ្នកផ្សេងទៀតអាចមិនទទួលការណ៍បែបនេះ ថាជាការព្យាករណ៍ វិវរណៈ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធនោះទេ ប៉ុន្តែបើពួកគេអាចយល់ពីពួកយើង នោះពួកគេត្រូវតែយល់ថាយើងទទួលនូវការណ៍ទាំងនោះ ។

ព្រះអម្ចាស់បានបើកបង្ហាញដល់ យ៉ូសែប ស្ម៊ីធ នូវច្បាប់សុខភាព គឺជាពាក្យសម្ដីនៃប្រាជ្ញាវាងវៃតាំងពីយូរ គឺមុនពេលដែលពិភពលោកបានដឹងពីគ្រោះថ្នាក់ទាំងនោះមកម្ល៉េះ ។ ទាំងអស់គ្នាត្រូវបានបង្រៀនឲ្យជៀសវាងពី តែ កាហ្វេ ស្រា ថ្នាំជក់ និងពិតណាស់ គឺពីថ្នាំ និងសារធាតុញៀនផ្សេងៗ ដែលតែងតែអូសទាញដល់យុវវ័យរបស់យើង ។ ពួកអ្នកដែលគោរពវិវរណៈនេះ ត្រូវបានសន្យាថានឹងមានសុខភាពល្អ « នឹងរកឃើញប្រាជ្ញា និងផលថ្លៃវិសេសនៃចំណេះវិជ្ជា គឺជាសម្បត្តិដែលលាក់ទុក » ។[12]

នៅក្នុងវិវរណៈមួយទៀត ជាបទដ្ឋានរបស់ព្រះអម្ចាស់អំពីសីលធម៌ បានដាក់បញ្ញត្តថា អំណាចដ៏ពិសិដ្ឋដើម្បីបង្កើតជីវិត ត្រូវតែការពារ និងប្រើប្រាស់ តែរវាង បុរស និងស្ត្រី ដែលជាប្ដី និងប្រពន្ធប៉ុណ្ណោះ ។[13] ការប្រើអំណាចនេះខុស នឹងនាំឲ្យកើតមានអំពើបាបដ៏ធ្ងន់ធ្ងរ លើកលែងតែការខ្វាយឈាមជនឥតទោស និងបដិសេធព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ។ បើសិនជាមនុស្សម្នាក់រំលងច្បាប់ នោះគោលការណ៍នៃការប្រែចិត្តបង្រៀនពីរបៀបដែលអាចលប់ចេញនូវអានុភាពនៃអំពើរំលងនេះ ។[14]

មនុស្សគ្រប់គ្នាត្រូវបានសាកល្បង ។ មនុស្សម្នាក់អាចគិតថា វាមិនយុត្តិធម៌ទេដែលយើងមានការការល្បួងជាក់លាក់មួយដែលអ្នកដទៃទៀតគ្មាន ប៉ុន្តែនេះគឺជាគោលបំណងនៃជីវិតរមែងស្លាប់នេះ---គឺដើម្បីទទួលការសាកល្បង ។ ហើយចម្លើយគឺដូចគ្នាសម្រាប់មនុស្សគ្រប់គ្នា ៖ យើងត្រូវតែ ហើយយើងអាចតទល់ជាមួយការល្បួងគ្រប់ប្រភេទទាំងអស់ ។

« ផែនការនៃសុភមង្គលដ៏មហិមា »[15] គឺផ្អែកទៅលើជីវិតក្រុមគ្រួសារ ។ ស្វាមីគឺជាមេគ្រួសារ ហើយប្រពន្ធជាបេះដូងនៃផ្ទះ ដោយការរៀបការជាដៃគូស្មើគ្នា ។ បុរសពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ គឺជាបុរសនៃក្រុមគ្រួសារដ៏មានការទទួលខុសត្រូវម្នាក់ ហើយស្មោះត្រង់ចំពោះដំណឹងល្អ ។ គាត់ជាស្វាមី និងឪពុកដែលមានការខ្វល់ខ្វាយ និងភក្ដីភាព ។ គាត់គោរពភាពជាស្ត្រី ។ ភរិយាគាំទ្រដល់ស្វាមីរបស់គាត់ ។ ទាំងឪពុកនិងម្ដាយ ចិញ្ចឹមបីបាច់ភាពល្អតលាស់ខាងវិញ្ញាណនៃកូនៗរបស់ពួកគេ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានបង្រៀនឲ្យស្រឡាញ់គ្នាទៅវិញទៅមក និងត្រូវឲ្យអភ័យទោសចំពោះកំហុសទាំងឡាយ ។

ជីវិតរបស់ខ្ញុំបានផ្លាស់ប្ដូរដោយលោកអយ្យកោដ៏សុចរិតម្នាក់ ។ ពេលគាត់នៅក្មេង គាត់បានរៀបការជាមួយស្ត្រីជាទីស្រឡាញ់របស់គាត់ ។ ពួកគាត់ស្រឡាញ់គ្នាខ្លាំងណាស់ ហើយមិនយូរប៉ុន្មាននាងក៏មានផ្ទៃពោះកូនដំបូង ។

នៅយប់ដែលត្រូវសម្រាលនោះ មានបញ្ហាក្នុងការសម្រាល ។ គ្រូពេទ្យដែលមានតែម្នាក់នោះ បានទៅឯជនបទដើម្បីមើលថែអ្នកជំងឺ ។ បន្ទាប់ពីឈឺពោះអស់រយៈពេលជាច្រើនម៉ោងមក ស្ថានភាពរបស់ម្ដាយធ្លាក់ក្នុងសភាពអស់សង្ឃឹម ។ ទីបំផុត គ្រូពេទ្យបានមកដល់ ។ នៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ គាត់បានធ្វើការសម្រាលយ៉ាងឆាប់រហ័ស ហើយមិនយូរប៉ុន្មាន ទារកបានកើតមក ហើយបញ្ហាលំបាកនោះហាក់ដូចជាបានរួចផុតហើយ ។ ប៉ុន្តែ ប៉ុន្មានថ្ងៃក្រោយមក ម្ដាយវ័យក្មេងបានស្លាប់ដោយសារតែមេរោគឆ្លងដែលគ្រូពេទ្យបានព្យាបាលនៅផ្ទះមួយផ្សេងទៀតនៅយប់ដដែលនោះ ។

ជីវិតបុរសវ័យក្មេងនោះត្រូវខ្ទេចខ្ទាំ ។ ជាច្រើនសប្ដាហ៍បានកន្លងផុតទៅ ទុក្ខសោករបស់គាត់កាន់តែធ្ងន់ធ្ងរទៅៗ ។ គាត់មិនបានគិតចំពោះអ្នកផ្សេងទៀតទេ ហើយនៅក្នុងភាពល្ងីងល្ងើរចត់របស់គាត់ គាត់បានគំរាមកំហែងអ្នកដទៃ ។ បើរឿងនេះកើតឡើងក្នុងពេលសព្វថ្ងៃនេះ គាត់ប្រាកដជានឹងត្រូវបានជំរុញឲ្យប្ដឹងគ្រូពេទ្យនោះព្រោះតែការព្យាបាលដែលគ្មានវិជ្ជាជីវៈ ដោយទោះជាលុយអាចដោះស្រាយបញ្ហាអ្វីក៏បានក្ដី ។

យប់មួយ មានគេមកគោះទ្វាររបស់គាត់ ។ ក្មេងស្រីតូចម្នាក់បាននិយាយយ៉ាងសាមញ្ញថា « ប៉ាខ្ញុំចង់អញ្ជើញពូឲ្យទៅផ្ទះយើង ។ គាត់ចង់និយាយជាមួយពូ ។

« ប៉ាខ្ញុំ » គឺជាប្រធានស្តេក ។ ដំបូន្មានពីអ្នកដឹកនាំដ៏ឈ្លាសវៃនោះគឺសាមញ្ញ « ចន ទុករឿងនោះមួយឡែកទៅ ។ គ្មានអ្វីដែលប្អូនអាចធ្វើដើម្បីឲ្យនាងត្រឡប់មកវិញនោះទេ ។ អ្វីក៏ដោយដែលប្អូនធ្វើនឹងធ្វើឲ្យវាកាន់តែធ្ងន់ធ្ងរទៅៗ ។ ចន ទុករឿងនោះមួយឡែកទៅ » ។

នេះជាការសាកល្បងសម្រាប់មិត្តរបស់ខ្ញុំ ។ តើឲ្យគាត់ទុកវាមួយឡែកដូចម្តេចទៅ ? គាត់បានធ្វើកំហុសដ៏ធំមួយ ។ គាត់ពិបាកក្នុងការគ្រប់គ្រងខ្លួនឯង ហើយទីបំផុត បានកំណត់ថា គាត់គួរតែគោរព និងធ្វើតាមដំបូន្មាននៃប្រធានស្តេកដ៏ឈ្លាសវៃនោះ ។ គាត់នឹងទុកវាមួយឡែក ។

គាត់បាននិយាយថា « ខ្ញុំជាមនុស្សចាស់ម្នាក់ពីមុនពេលដែលខ្ញុំយល់ ហើយទីបំផុតអាចមើលឃើញពីគ្រូពេទ្យជនបទដ៏កម្សត់ម្នាក់នោះ---ធ្វើការហួសម៉ោង ទទួលកម្រៃតិចតួច រត់យ៉ាងហត់នឿយពីអ្នកជំងឺមួយទៅអ្នកជំងឺមួយទៀត ជាមួយនឹងថ្នាំបន្តិចបន្តួច គ្មានមន្ទីរពេទ្យ ឧបករណ៍តិចតួច មានបញ្ហាក្នុងការសង្គ្រោះជីវិត ប៉ុន្តែបានជោគជ័យភាគច្រើន ។ គាត់បានមកក្នុងគ្រាដ៏លំបាក នៅពេលដែលជីវិតពីរនាក់ស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ហើយគាត់បានព្យាបាលដោយមិនបង្អង់ឡើយ ។ ទីបំផុត ខ្ញុំបានយល់ ! បើខ្ញុំមិនបានទុករឿងនោះមួយឡែកទេ ខ្ញុំនឹងបំផ្លាញជីវិតខ្លួនឯង និងជីវិតផ្សេងទៀត » ។

គាត់បានអរគុណព្រះអម្ចាស់ជាច្រើនដង ចំពោះអ្នកដឹកនាំបព្វជិតភាពដ៏ឈ្លាសវៃ ដែលបានផ្តល់ដំបូន្មានយ៉ាងសាមញ្ញ « ចន ទុករឿងនោះមួយឡែកទៅ » ។
នៅជុំវិញយើង យើងឃើញសមាជិកសាសនាចក្រ ដែលមានការអាក់អន់ចិត្ត ។ អ្នកខ្លះអន់ចិត្តចំពោះឧប្បត្តិហេតុនៅក្នុងប្រវត្តិសាសនាចក្រ ឬអន់ចិត្តជាមួយអ្នកដឹកនាំ ហើយបានរងទុក្ខអស់មួយជីវិតរបស់គេ ហើយមិនអាចមើលរំលងកំហុសរបស់អ្នកដទៃ ។ ពួកគេមិនទុកវាមួយឡែកទេ ។ ពួកគេបានក្លាយជាអសកម្ម ។

ឥរិយាបថនោះគឺស្រដៀងគ្នាទៅនឹងបុរសម្នាក់ដែលត្រូវបានវាយដោយដំបងមួយអញ្ចឹង ។ មនុស្សដែលអាក់អន់ចិត្តនោះ គឺគាត់យកដំបងមួយ ហើយវាយក្បាលខ្លួនឯងពេញមួយជីវិតរបស់គាត់ ។ ល្ងង់ម្ល៉េះ ! គួរឲ្យស្តាយម្ល៉េះ ! ការសងសឹកប្រភេទនោះគឺជាការដាក់ទោសខ្លួនឯង ។ បើសិន អ្នកអាក់អន់ចិត្ត ចូរអភ័យទោស បំភ្លេចវា ហើយទុកវាមួយឡែកទៅ ។

ព្រះគម្ពីរមរមនមាននូវការព្រមាននេះ ៖ « ហើយឥឡូវនេះ ប្រសិនបើមានកំហុសណាមួយ គឺជាសេចក្តីភាន់ច្រឡំរបស់មនុស្សទេ ហេតុដូច្នេះហើយ សូមកុំថ្កោលទោសដល់វត្ថុដែលជារបស់ផងព្រះឡើយ ដើម្បីឲ្យអ្នករាល់គ្នាអាចបានឃើញថាគ្មានទោស នៅចំពោះវេទិកាជំនុំជម្រះនៃព្រះគ្រីស្ទ » ។[16]

ពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ គឺដូចជាបុគ្គលសាមញ្ញម្នាក់ ។ ឥឡូវនេះ យើងនៅគ្រប់ទីកន្លែងក្នុងពិភពលោក មានពួកយើង 14 លាននាក់ ។ នេះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ ។ យើងត្រូវបានបង្រៀនឲ្យនៅក្នុងលោកិយ ប៉ុន្តែមិនមែនជារបស់លោកិយទេ ។[17] ហេតុដូច្នោះហើយ យើងរស់នៅដោយសាមញ្ញក្នុងក្រុមគ្រួសារសាមញ្ញ ក្នុងចំណោមប្រជាពលរដ្ឋទូទៅ ។

យើងត្រូវបានបង្រៀន មិនឲ្យកុហក ឬលួច ឬបន្លំ ។[18] យើងមិនប្រើភាសាអសុរោះនោះទេ ។ យើងវិជ្ជមាន និងរីករាយ និងមិនភ័យខ្លាចចំពោះជីវិតរស់នៅ ។

យើង « យល់ព្រមទួញយំជាមួយនឹងអ្នកណាដែលទួញយំ...ហើយកម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការកម្សាន្តទុក្ខ ហើយឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និងគ្រប់សេចក្តី និងគ្រប់ទីកន្លែង » ។[19]

បើសិនជានរណាម្នាក់កំពុងស្វែងរកសាសនាចក្រមួយដែលតម្រូវឲ្យអ្នកធ្វើតិចតួច នេះមិនមែនជាសាសនាចក្រដែលអ្នកនោះកំពុងស្វែងរកនោះទេ ។ វាមិនងាយស្រួលក្នុងការធ្វើជាពួកបរិសុទ្ធម្នាក់នោះទេ ប៉ុន្តែ នៅទីបំផុត វាគឺជាផ្លូវត្រូវតែមួយគត់ ។

ដោយមិនគិតពីការផ្ទុយ ឬ « សង្គ្រាម ពាក្យចចាមអារ៉ាមអំពីសង្គ្រាម និងផែនដីរញ្ជួយនៅកន្លែងផ្សេងៗ »[20] នោះគ្មានអំណាច ឬឥទ្ធិពលអ្វី អាចបញ្ឈប់កិច្ចការនេះបានទេ ។ យើងគ្រប់គ្នាអាចត្រូវបានដឹកនាំ ដោយវិញ្ញាណនៃវិវរណៈ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ « ដូចជាមនុស្សណាម្នាក់លាតដៃខ្សោយទៅបញ្ឈប់ទន្លេមិសសួរី នៅក្នុងដំណើរវាដែលបានសម្រេចទុក ឬបង្វែរទឹកហូរបញ្ច្រាសយ៉ាងណា នោះក៏ដូចជាបង្អាក់ព្រះដ៏មានមហិទ្ធិឫទ្ធិ ពីការចាក់តម្រិះពីស្ថានសួគ៌ មកលើក្បាលនៃពួកបរិសុទ្ធថ្ងៃចុងក្រោយយ៉ាងនោះដែរ » ។[21]

បើអ្នករាល់គ្នាកំពុងតែទ្រនូវបន្ទុកមួយចំនួន ចូរបំភ្លេចវា ហើយទុកមួយឡែកសិន ។ សូមធ្វើការអភ័យទោសឲ្យបានច្រើន និងការប្រែចិត្តតិចតួច នោះអ្នកនឹងមានព្រះវិញ្ញាណនៃព្រះវិញ្ញាណបរិសុទ្ធ ហើយបានបញ្ជាក់ដោយទីបន្ទាល់ដែលមិនបានដឹងថាវាកើតមាន ។ អ្នកនឹងត្រូវបានមើលថែ និងប្រទានពរឲ្យ ---ទាំងអ្នកនិងគ្រួសារអ្នក ។ នេះគឺជាការអញ្ជើញមួយឲ្យមករកទ្រង់ ។ ព្រះវិហារនេះ ---ដែលសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជា« គឺជាព្រះវិហារពិតហើយសកម្មតែមួយគត់នៅលើផ្ទៃផែនដីទាំងមូល »[22] ដោយតាមរយៈការប្រកាសរបស់ទ្រង់ផ្ទាល់ ---គឺជាទីកន្លែងដែលយើងរកឃើញនូវ« ផែនការនៃសុភមង្គលដ៏មហិមា »23 ខ្ញុំសូមថ្លែងទីបន្ទាល់ពីការណ៍នេះនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។

កំណត់ចំណាំ

1. David Danielle, Introduction to Tyndale´s New Testament បកប្រែដោយWilliam Tyndale [ឆ្នាំ 1989] ទំព័រ viii ។
2. David Danielle, Introduction to Tyndale´s New Testament ទំព័រ ix ។
3. នីហ្វៃទី3 27:2–5, 7–8 ។
4. សារលិខិតរបស់គណៈប្រធានទីមួយ ថ្ងៃទី 23 ខែ កុម្ភៈ ឆ្នាំ 2001 ។
5. នីហ្វៃទី2 25:26 ។
6. សូមមើល ម៉ូសេ 5:8; បុណ្យជ្រមុជទឹក ៖ នីហ្វៃទី2 31:12; 11:27; 18:16; ប្រសិទ្ធពរដល់អ្នកឈឺ ៖ គោលលទ្ធិ និងសេចក្ដីសញ្ញា 42:44; ការប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ៖ មរ៉ូណៃ 2:2; បព្វជិតភាព ៖ មរ៉ូណៃ 3:1–3; ពិធីសាក្រាម៉ង់ ៖ មរ៉ូណៃ 4:1–3; អព្ភូតហេតុ ៖ គោលលទ្ធិ និងសេចក្ដីសញ្ញា 84:66–69 ។
7. សូមមើល មាត្រានៃសេចក្ដីជំនឿ 1:6 ។
8. សូមមើល កិច្ចការ 1:3–11 ។
9. កិច្ចការ 2:2–4 ។
10. សូមមើល កិច្ចការ 2:38 ។
11. គោលលទ្ធិ និងសេចក្ដីសញ្ញា 1:20 ។
12. គោលលទ្ធិ និងសេចក្ដីសញ្ញា 89:19 ។
13. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* ខែ តុលា ឆ្នាំ 2004 ទំព័រ 49 *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 102 ។
14. អាលម៉ា 39:4–6 ។
15. អាលម៉ា 42:8 ។
16. ព្រះគម្ពីរមរមន ទំព័រចំណងជើង ។
17. សូមមើល យ៉ូហាន 17:14–19 ។
18. សូមមើល និក្ខមនំ 20:3–17 ។
19. ម៉ូសាយ 18:9 ។
20. មរមន 8:30 ។
21. គោលលទ្ធិ និងសេចក្ដីសញ្ញា 121:33 ។